**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ ២២/២០០៣ កបធ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៣

**ជំរាបមក**

**ឯកឧត្តម ឯក វណ្ណឌី**

**តាមរយៈប្រធានរដ្ឋសភា**

**កម្មវត្ថុ** : សំណើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយឡើងវិញមាត្រា ៧៨ និង មាត្រា ៨២នៃរដ្ឋធម្មនុញ្ញ

**យោង** : លិខិតរបស់ឯកឧត្តម ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតរបស់ឯកឧត្តមដូចក្នុងកម្មវត្ថុ និងយោងខាងលើនេះរួចហើយ ប៉ុន្តែមិនអាចទទួលយកមកពិនិត្យបានទេ ដោយមូលហេតុដូចខាងក្រោម :

១- ជាគោលការណ៍ច្បាប់ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ( មាត្រា ១៤២ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ២៣នៃច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

លិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ២០/២០០៣ កបធ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣ ជាសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ ។

២- ការសុំបកស្រាយមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ តូវមានការបញ្ជាក់អំពីបញ្ហាដែលមានកើតឡើងជាក់ស្តែងក្នុងការអនុវត្តន៍ ឬ មូលហេតុត្រឹមត្រូវដែលនាំឱ្យមានការសុំបកស្រាយនោះ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចជាអ្នកធ្វើបទឧទ្ទេសនាមអំពីទ្រឹស្តី បានឡើយ ។ សូមអានលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៩/២០០២ កបថ .សជណ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ដែល ឆ្លើយទៅប្រធានរដ្ឋសភា។

ម៉្យាងទៀត ក្រុមប្រឹក្សាធម្មនុញ្ញ សូមធ្វើការកត់សំគាល់ថា នៅក្នុងលិខិតរបស់ឯកឧត្តម មានអ្នកតំណាងរាស្ត្រខ្លះបានបាត់បង់គុណវុឌ្ឍិជាតំណាងរាស្ត្រអស់ហើយ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**